# របាយការណ៍សង្ខេប ពីស្ថានភាព
# មេរោគអេដស៍/ជំងឺអេដស៍ នៅខេត្តកំពង់ចាម
# បេសកកម្ម ថ្ងៃទី២៣-២៥ ខែ មេសា ឆ្នាំ ២០១៥

**I-ក្រុមការងារចុះបេសកម្មៈ**

១- ឯកឧត្តមវេជ្ជ. ជា ប៉ោ២- វេជ្ជ.រ៉ឹង យ៉ាណាត៣- វេជ្ជ. សូរ សុភី៤- លោក ហាង វិបុល៥- វេជ្ជ.ហេង ហៃ

**II-ទីកន្លែងចុះត្រួតពិនិត្យៈ**

- លេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត
- ការិយាល័យអេដស៍ខេត្ត
- តំណាងអង្គការ
- មន្ទីរពេទ្យបង្អែកកំពង់ចាម

**III-លទ្ធផលៈ**

**១-ស្ថានភាពនៃការឆ្លងរាលដាលមេរោគអេដស៍នៅក្នុងខេត្តៈ**

- ពីឆ្នាំ២០១៤រហូតដល់ត្រីមាសទី១ឆ្នាំ ២០១៥នេះ ទូទាំងខេត្តមានករណីឆ្លងមេរោគអេដស៍ថ្មីចំនួន **១៨១**នាក់។
- ចំនួននារីបំរើតាមគ្រឹះស្ថានកំសាន្តសប្បាយមាន៖ **៦៧៩**នាក់ ក្នុងនោះ **៥៧៨**នាក់បានទទួលការអប់រំ។
- ចំនួននារីម៉ាស្សាមាន៖**១២៨**នាក់
- ចំនួនបុរសស្រឡាញ់បុរសមាន៖ **៤៩៥**នាក់ ក្នុងនោះ **៣២១**នាក់បានទទួលការអប់រំ.
- ចំនួនក្រុមកែភេទមាន៖ **៩០**នាក់ ក្នុងនោះ **៧៦**នាក់បានទទួលការអប់រំ.
- ចំនួនអ្នកប្រើគ្រឿងញៀនក្រៅពីចាក់តាមសរសៃមាន៖ **២៣០**នាក់
- ចំនួនអង្គការធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍នៅក្នុងខេត្តមាន៖ ១៤អង្គារ (PSOD, MHC, BSDA, FHI360, RHAC, NPS, SPAEN, Women, CHEC, Sunrise, CPN+, Flagship, AHF, AUA.).

**២-បញ្ហាដែលជួបប្រទះនៅក្នុងខេត្តៈ**

- ✓ ការស្នើសុំ Test Determine (Rapid Test/ Finger prick) ពីមជ្ឈមណ្ឌលជាតិ (NCHARD) មិនបានគ្រប់តាមតម្រូវការនិងTest ខ្លះកៀកនិងកាលបរិច្ឆេទប្រើប្រាស់ឬគ្មានគុណភាពមិនអាចប្រើបាន។
- ✓ ការចំណាកស្រុកដោយកក្តាជីវភាពនិងខ្វះថវិកាធ្វើដំណើរមកបើកថ្នាំប្រឆាំងមេរោគអេដស៍។
- ✓ អ្នកផ្ទុកមេរោគអេដស៍ ដល់អាយុពេញវ័យត្រូវរៀបការ មិនហ៊ានប្រាប់គូរដណ្តឹង។
- ✓ ប្រពន្ធផ្ទុកមេរោគអេដស៍ មិនហ៊ានប្រាប់ប្តីឬសង្សារ។
- ✓ ខ្វះថ្នាំ OIs នៅគ្រប់ ODs ចាប់ពីខែ១១ ឆ្នាំ២០១៤ ដល់ខែ៣ ឆ្នាំ២០១៥។
- ✓ នៅ OD ជើងព្រៃអត់មានគ្រូពេទ្យព្យាបាលអ្នកជំងឺអេដស៍។

- ✓ ខ្វះ Test Finger prick នៅ OD កំពង់ចាម/កំពង់សៀម។
- ✓ មណ្ឌលសុខភាពខ្លះបណ្តុះបណ្តាលហើយ តែអត់មាន Test ធ្វើ ឬមានតែមិនគ្រប់គ្រាន់។
- ✓ តាមរោងចក្របើសិនថៅកែដឹងថា បុគ្គលិក រឺកម្មករមានផ្ទុកមេរោគអេដស៍ នោះត្រូវបញ្ឈប់ពីការងារ។

**៣- សំណូមពរ៖**

- ○ គួរមានកញ្ចប់ថវិកាសំរាប់ការងារអេដសិក្នុងផែនការអភិវឌ្ឍន៍ ឃុំ/សង្កាត់ និងក្នុងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ/សង្កាត់ ។
- ○ បន្តលើកទឹកចិត្តដល់មន្ត្រីធ្វើការងារអេដស៍ ។
- ○ ត្រូវលើកទឹកចិត្ត និងជួយរកការងារអោយអ្នករស់នៅជាមួយមេរោគអេដស៍។
- ○ ត្រូវមានថ្នាំ OIs គ្រប់គ្រាន់សំរាប់ព្យាបាលជំងឺឱកាសនិយម។
- ○ ត្រូវមាន Test គ្រប់គ្រាន់ និងមានគុណភាព ដើម្បីស្វែងរកពីការចំលងថ្មីនិង Test សំរាប់មើល TauxCD4 ដើម្បីតាមដានពីការវិវត្តន៍នៃជំងឺ។
- ○ ស្នើសុំក្រសួងការងារ និងក្រសួងសង្គមកិច្ចជួយអន្តរាគមន៍ដល់រោងចក្រចំពោះអ្នកផ្ទុក មេរោគអេដស៍ពេលសុំច្បាប់មកបើកថ្នាំ។

**៤-សេចក្តីសន្និដ្ឋាន:**

តាមការចុះពិនិត្យស្ថានភាពផ្ទាល់នៅមូលដ្ឋានយើងឃើញថាការឆ្លងថ្មីនិងអ្នកស្លាប់ថ្មីនៅតែបន្តកើតមានឡើងជារៀងរាល់ថ្ងៃដោយហេតុផលផ្សេងៗជាច្រើនដូចជាកំណើនកន្លែងសេវាកំសាន្ត, ភាពហឹហានិងប្រពន្ធ័បច្ចេកវិជ្ជា, ការធ្វើចំណាកស្រុកនិងបោះបង់ការព្យាបាល,ការខ្វះថ្នាំព្យាបាលជំងឺឱកាសនិយម (ថ្នាំ OIs) ..។ល។ និងស្របពេលដែលថវិកាជំនួយរបស់អង្គការមួយចំនួនធំ មានការថយចុះយ៉ាងគំហុកនោះគោលដៅ ៣.០ ( គ្មានការរើសអើង គ្មានការចម្លងថ្មី គ្មានការស្លាប់) នៅឆ្នាំ២០២០ វាជាការលំបាកខ្លាំងណាស់ ហើយរលកទីពីរនៃមេរោគអេដស៍ នឹងអាចកើតមានក្នុងពេលណាមួយជាក់ជាមិនខាន៕

ធ្វើនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៥